# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

-សាលក្រមព្រហ្មទណ្ឌ

លេខ: ៧៨ "គ១ក្រ១០"

ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២២

-សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៩៩០

ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០២១

-សំណុំរឿងស៊ើបសួរ

លេខ: ១៩៩៥

ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២១

-សំណុំរឿងជំនុំជម្រះ

លេខ: ៣៥៤៩

ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈនៅ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២១ វេលាម៉ោង ០២ និង ០០នាទី រសៀល នៅសាលសវនាការទី ៣ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា។

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា។

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា។

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

### មេធាវីការពារឱ្យជនជាប់ចោទ

-លោកស្រី [redacted] បូរ៉ា អត្តលេខ ៧៥៤ និងលោក [redacted] សុធារ៉ា អត្តលេខ ២១៧២T មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ ជា ភូមិរ៉ា។

ដើម្បីជំនុំជម្រះលើ សំណុំរឿងព្រហ្មទណ្ឌលេខ ១៩៩០ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] SHENG ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិ ចិន មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅ ខេត្តគ័ងតុង ប្រទេសចិន មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ [redacted] សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] CHANG "រស់" ម្តាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារនៅប្រទេសចិនរយៈពេល ០២ ឆ្នាំ ១០ ខែ ពីបទ៖ គ្រឿងញៀន ។ (ក្នុងឃុំ-ម១)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៤៧០ "ម" ដ.ឃ.ជ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២១។

២-ឈ្មោះ [redacted]រ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ ជាងបាញ់ថ្នាំឈើ ទីកន្លែងកំណើតនៅ ភូមិដើមចាន់ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅ [redacted] អំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ទោសពីមុន គ្មាន។ (ក្នុងឃុំ - ម២)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៤៦៩ "ម" ដ.ឃ.ជ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២១។

ជាប់ចោទពីបទ៖ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ផ្លូវលេខ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ និងនៅ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី ២ ខណ្ឌច្បារអំពៅ



Scanned with CamScanner

រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ

កាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២១ វេលាម៉ោង ១៨ និង ១០នាទី មន្ត្រីនគរបាល នៃការិយាល័យស៊ើបការណ៍ខាងក្រៅ នៃមន្ទីរប្រឆាំងគ្រឿងញៀន បានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] SHENG ភេទប្រុស អាយុ ៣៣ ឆ្នាំ នៅចំណុចក្បែរស្តុបក្បាលថ្នល់ ផ្លូវ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ និងបានដកហូតក្រាមពណ៌ សថ្លា ចំនួន ០២ កញ្ចប់ ទម្ងន់ ១.៦៧ (មួយ កណ្តក់សញ្ញា ហុកសិបប្រាំពីរ) ក្រាម។ រហូតដល់វេលាម៉ោង ១៨ និង ៣០នាទី ថ្ងៃខែឆ្នាំដូចខាងលើ មន្ត្រីនគរបាលបានបន្តឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ នៅចំណុចភូមិដើមចាន់ សង្កាត់ច្បារអំពៅទី ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងដកហូតបានក្រាមពណ៌ សថ្លា ទម្ងន់ ០.១២ (សូន្យ កណ្តក់សញ្ញា ដប់ពីរ) ក្រាម។

បានឃើញ របាយការណ៍លេខ ៣៥៤ រ.ប.ក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៥៤១ អ.យ.ដ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣២៥២ អ.យ.ដ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦៩០ "ព" ជ.ដ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] SHENG បានឆ្លើយថា៖ ខ្ញុំមិនទទួលស្គាល់ចម្លើយរបស់ខ្ញុំនៅសមត្ថកិច្ចទេ ព្រោះអ្នកបកប្រែនិយាយស្តាប់គ្នាមិនបាន។ ខ្ញុំបានស្គាល់ស្ត្រីម្នាក់តាមហ្វេសប៊ុក ហើយទំនាក់ទំនងគ្នាតាមរយៈការផ្ញើសារគ្នាទៅវិញទៅមក។ ថ្ងៃមួយ ស្ត្រីម្នាក់នោះបានឱ្យខ្ញុំរកទិញគ្រឿងញៀនប្រភេទម្សៅ ខេ (ខេតាមីន) ឲ្យគាត់ ប៉ុន្តែខ្ញុំប្រាប់ថា គ្មានទេ។ លុះមកដល់ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២១ ខ្ញុំ និងស្ត្រីម្នាក់នោះបានណាត់ជួបគ្នានៅផ្ទះជួលរបស់ខ្ញុំ ហើយគាត់បាននាំស្ត្រីម្នាក់ទៀតមកជាមួយគ្នា ពេលទៅដល់ផ្ទះជួលរបស់ខ្ញុំ ស្ត្រីម្នាក់ទៀតដែលខ្ញុំទើបស្គាល់បានសួររកគ្រឿងញៀន ខ្ញុំក៏ប្រាប់គាត់ថា គ្មានទេ។ នៅវេលាម៉ោង ១៨ និង ០០នាទី ស្ត្រីម្នាក់នោះបានប្រើខ្ញុំទៅយកគ្រឿងញៀនពីបុរសម្នាក់ ហើយខ្ញុំក៏ទៅជាមួយគាត់ ដោយពេលទៅដល់ទីនោះ ស្ត្រីម្នាក់នោះ គឺជាអ្នកប្រគល់ប្រាក់ឲ្យទៅអ្នកលក់នោះផ្ទាល់ ពេលទិញគ្រឿងញៀនបាន ខ្ញុំ និងស្ត្រីម្នាក់ដែលខ្ញុំទើបស្គាល់នោះជិះម៉ូតូកង់បីចេញមកវិញ ដើម្បីយកគ្រឿងញៀនទៅប្រើប្រាស់ជាមួយគ្នានៅផ្ទះជួលរបស់ខ្ញុំ តែនៅតាមផ្លូវត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។ ពេលសមត្ថកិច្ចចាប់ឆែកឆេរ គឺមិនមានឃើញអ្វីនៅលើខ្លួនខ្ញុំទេ ហើយខ្ញុំមិនចេះប្រើប្រាស់គ្រឿងញៀនទេ ខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។
- ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្ញុំមិនទទួលស្គាល់ចម្លើយនៅសមត្ថកិច្ចទេ។ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀនប្រហែល ០២ ខែ មុនពេលចាប់ខ្លួន ហើយខ្ញុំចេះប្រើប្រាស់តាមរយៈមិត្តភក្តិឈ្មោះ សាល ដែលនៅក្នុងភូមិជាមួយគ្នា។ ឈ្មោះ សាល ធ្លាប់ឲ្យខ្ញុំយកគ្រឿងញៀនឲ្យគេបានចំនួន ០២ ដង ដោយលើកទី ១ យកទៅឲ្យប្រុសជនជាតិចិនម្នាក់ ចំនួន ០១ កញ្ចប់ តម្លៃប្រហែល ៣០$ (សាមសិបដុល្លារអាមេរិក) នៅម្តុំស្ពានអាកាសស្ទឹងមានជ័យ ជិតពេទ្យ



Scanned with CamScanner

រុស្ស៊ី ហើយឈ្មោះ សាល ឱ្យប្រាក់ខ្ញុំចំនួន ១០$ (ដប់ដុល្លារអាមេរិក)។ ខ្ញុំមិនបានដឹងថាឈ្មោះ សាល ឱ្យខ្ញុំយកគ្រឿងញៀនទៅឱ្យគេទេ ព្រោះដាក់ក្នុងថង់ទឹកក្រូច។ លើកទី២ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២១ ខ្ញុំយកគ្រឿងញៀនទៅឱ្យប្រុសជនជាតិចិនម្នាក់ ចំនួន ០២ កញ្ចប់ នៅជិតផ្សារច្បារអំពៅ មុំច្រាំងបាក់ ហើយមិនដឹងថាបានប្រាក់ប៉ុន្មានទេ ព្រោះមិនបានរាប់ប្រាក់នោះ រួចខ្ញុំក៏ត្រលប់ទៅវិញ ប៉ុន្តែតាមផ្លូវត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង។ ពេលដែលសមត្ថកិច្ចចាប់ឃាត់ខ្លួនខ្ញុំ គឺបានដកហូតគ្រឿងញៀនចំនួន ០១ កញ្ចប់តូច, ប្រាក់ចំនួន ២៤០$ (ពីររយសែសិបដុល្លារអាមេរិក) ដែលជាប្រាក់ខែរបស់ខ្ញុំ, ប្រាក់មួយចំនួនដែលបានពីលក់គ្រឿងញៀនឱ្យជនជាតិចិន, ម៉ូតូចំនួន ០១ គ្រឿង និងទូរស័ព្ទ ០១ គ្រឿង។ គ្រឿងញៀនចំនួន ០១ កញ្ចប់នោះ គឺខ្ញុំទិញពីឈ្មោះ សាល ដើម្បីទុកប្រើប្រាស់ខ្លួនឯង។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់, ស្តាប់ចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងរួចមក ដូចនេះ តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted]SHENG ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted]រ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣២៥២ អ.យ.ដ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២១ ទុកជាបានការដដែល។ សូមតុលាការពិនិត្យពិចារណានិងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

មេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយរបស់កូនក្តីខ្លួន ឃើញថា កូនក្តីខ្លួនមិនបានដឹងថាឈ្មោះ សាល ឱ្យកូនក្តីខ្លួនយកគ្រឿងញៀនទៅឱ្យអ្នកដទៃឡើយ ព្រោះពេលនោះ គ្រឿងញៀនត្រូវបានខ្ចប់ក្នុងថង់ទឹកក្រូច។ កូនក្តីខ្លួនមានអាយុ ១៧ឆ្នាំ ដែលជាអនីតិជននៅឡើយ ហេតុនេះ សូមតុលាការសម្រេចផ្តល់ស្ថានសម្រាលទោសមកដល់កូនក្តីខ្លួនផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] SHENG និងឈ្មោះ [redacted]រ៉ា បាននិយាយសំដីចុងក្រោយបង្អស់ប្រហាក់ប្រហែលគ្នាថា៖ សុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យរូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

- ពិតជាមានករណី រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បានកើតឡើងនៅចំណុចផ្លូវលេខ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ និងនៅ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២១ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] SHENG ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted]រ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ប្រាកដមែន។



Scanned with CamScanner

- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] SHENG និងឈ្មោះ [redacted]រ៉ា ឃើញថា៖ ជនជាប់ចោទបានឆ្លើយបដិសេធមិនទទួលស្គាល់នូវការចោទប្រកាន់នេះទេ ព្រោះខ្លួនមិនបានប្រព្រឹត្តឡើយ។

ដោយឡែក តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]SHENG បានឆ្លើយថា ខ្លួនពិតជាបានទៅទិញគ្រឿងញៀនជាមួយស្ត្រីម្នាក់មិនស្គាល់ឈ្មោះ ដើម្បីយកមកប្រើប្រាស់រួមគ្នាមែន ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅពេលដែលត្រលប់មកផ្ទះជួលវិញ ដោយបានរកឃើញគ្រឿងញៀនចំនួន ០១ កញ្ចប់។ តាមរយៈចម្លើយរបស់ជនជាប់ចោទនេះ ឃើញថា សកម្មភាពរបស់ជនជាប់ចោទដែលបានប្រព្រឹត្តត្រូវបានច្បាប់កំណត់ថាជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។

ឯជនជាប់ចោទឈ្មោះ [redacted]រ៉ា បានឆ្លើយថា ឈ្មោះ សាល ធ្លាប់ឲ្យខ្លួនយកគ្រឿងញៀនទៅឲ្យគេ និងឲ្យប្រាក់ជាថ្លៃឈ្នួល ហើយនៅថ្ងៃកើតហេតុ ជនជាប់ចោទត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន និងឆែកឆេររកឃើញគ្រឿងញៀនបន្ទាប់ពីខ្លួនយកគ្រឿងញៀនទៅឲ្យជនជាតិចិន។ តាមរយៈចម្លើយរបស់ជនជាប់ចោទនេះ ឃើញថា ជនជាប់ចោទពិតជាបានធ្វើសកម្មភាព ដឹកជញ្ជូនគ្រឿងញៀនទៅឲ្យអ្នកដទៃ ដោយទទួលបានប្រាក់ជាកម្រៃដើងសារ ដែលអំពើនេះត្រូវបានច្បាប់កំណត់ថា ជាបទល្មើស ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

ហេតុនេះ ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted]SHENG និងឈ្មោះ [redacted]រ៉ា គឺគ្រាន់តែជាការឆ្លើយដោះសារ ដោយមិនមានភស្តុតាងណាមួយមកបង្ហាញ និងសាក្សីណាមួយច្បាស់លាស់ ដើម្បីអាចឲ្យតុលាការជឿជាក់បានឡើយ។

- ជនជាប់ចោទឈ្មោះ [redacted] SHENG និងឈ្មោះ[redacted]រ៉ា មានសមត្ថភាពយល់ដឹងច្បាស់លាស់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្តថា មានផលប៉ះពាល់ដល់សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដោយមិនមានសញ្ញាណាមួយបង្ហាញពីបញ្ហាស្មារតី ឬភាពមិនប្រក្រតីណាមួយឡើយ។ ជនជាប់ចោទមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលទោសព្រហ្មទណ្ឌ ដែលបានចែងកំណត់នៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- ផ្អែកតាមចម្លើយរបស់ជនជាប់ចោទខាងលើនេះ ឃើញថា មានភាពស៊ីសង្វាក់ទៅនឹងវត្ថុតាងជាគ្រឿងញៀនក៏ដូចជារបាយការណ៍របស់សមត្ថកិច្ច ដែលអាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] SHENG និងឈ្មោះ [redacted]រ៉ា ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

- វត្ថុចាប់យករួមមាន៖

១/ ស្រោមសំបុត្រពណ៌ គគីរ បិទជិត មានសរសេរថា៖

- ក្រាមពណ៌ សថ្លា ទម្ងន់ ០.១២ g (សូន្យ កណ្តក់សញ្ញា ដប់ពីរ ក្រាម) មេតំហ្វេតាមីន ដោយមានផ្តិតស្នាមមេដៃជនជនជាប់ចោទឈ្មោះ [redacted]រ៉ា និងមានចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌។

- ក្រាមពណ៌ សថ្លា ទម្ងន់ ១.៦៧ g (មួយ កណ្តក់សញ្ញា ហុកសិបប្រាំពីរ ក្រាម) កេតាមីន ដោយមានផ្តិតស្នាមមេដៃជនជាប់ចោទឈ្មោះ[redacted]SHENG និងមានចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌។

គប្បីរឹបអូសបំផ្លាញចោល។

២/ ទូរស័ព្ទ ០២ គ្រឿង (មិនដំណើរការ)៖ ម៉ាក HUAWEI ពណ៌ ស្វាយ ចំនួន ០១ គ្រឿងរបស់ឈ្មោះ CUI QI SHENG និងម៉ាក ALCATEL ពណ៌ ខ្មៅ ចំនួន ០១ គ្រឿង ពណ៌ ខ្មៅ ចំនួន ០១ គ្រឿងរបស់ឈ្មោះ [redacted]រ៉ា។

គប្បីសម្រេចពិនិត្យ និងពិចារណា។



Scanned with CamScanner

- តាមលទ្ធផលកោសលវិច័យលេខ ៣២២១០/២១ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២១ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសន្និដ្ឋានថា៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌គគីរ បិទជិត មានហត្ថលេខាគណៈកម្មការ, ត្រារបស់មន្ទីរប្រឆាំងគ្រឿងញៀន និងស្នាមមេដៃឈ្មោះ [redacted] និងឈ្មោះ [redacted] SHENG ជាប្រភេទក្រាមម្សៅថ្លា ពណ៌ ស ទម្ងន់ ១.៦៧២៥ ក្រាម មានលទ្ធផល វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ កេតាមីន គិតជាភាគរយនៃទម្ងន់គឺ ៧៥.៦០% (ចិតសិបប្រាំ កណ្ដក់សញ្ញា ហុកសិប ភាគរយ) ។

+ សំណាក ជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ដែលមានកម្រិតសុទ្ធ ៧៥.៦០%។ ដូច្នេះ

បរិមាណធាតុសុទ្ធគឺ៖ $\frac{1.67g \times 75.60}{100} = 1.2625$ក្រាម។

- ជនជាប់ចោទមានគ្រឿងញៀន ដែលមានសារធាតុញៀនឈ្មោះ កេតាមីន ជាប្រភេទក្រាមម្សៅ ហើយមានបរិមាណធាតុសុទ្ធសរុបគឺ៖ ១.២៦២៥ (មួយ កណ្ដក់សញ្ញា ពីរពាន់ប្រាំមួយរយម្ភៃប្រាំ) ក្រាម។

- តាមលទ្ធផលកោសលវិច័យលេខ ៣២២១១/២១ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២១ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសន្និដ្ឋានថា៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌គគីរ បិទជិត មានហត្ថលេខាគណៈកម្មការ, ត្រារបស់មន្ទីរប្រឆាំងគ្រឿងញៀន និងស្នាមមេដៃឈ្មោះ [redacted] និងឈ្មោះ [redacted] SHENG ជាប្រភេទក្រាមម្សៅថ្លា ពណ៌ ស ទម្ងន់ ០.១២៣៦ ក្រាម មានលទ្ធផល វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ ៧៣.៦៥% (ចិតសិបបី កណ្ដក់សញ្ញា ហុកសិបប្រាំ ភាគរយ) ។

+ សំណាក ជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រាម៉ាទឹកកក ឬ អាយ) ដែលមានកម្រិតសុទ្ធ ៧៣.៦៥%។ ដូច្នេះបរិមាណធាតុសុទ្ធគឺ៖ $\frac{0.12g \times 73.65}{100} = 0.0883$ក្រាម។

- ជនជាប់ចោទមានគ្រឿងញៀន ដែលមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ជាប្រភេទក្រាមម្សៅ (ហៅក្រាម៉ាទឹកកក ឬ អាយ) ហើយមានបរិមាណធាតុសុទ្ធសរុបគឺ: ០.០៨៨៣ (សូន្យ កណ្ដក់សញ្ញា សូន្យប្រាំបីរយប៉ែតសិបបី) ក្រាម។

- ជនជាប់ចោទឈ្មោះ CUI QI SHENG និងឈ្មោះ [redacted] បាននិយាយសំដីចុងក្រោយបង្អស់ប្រហាក់ប្រហែលគ្នាថា៖ សុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យរូបខ្លួនផង។

- មេធាវីការពារឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា៖ សូមតុលាការផ្ដល់ស្ថានសម្រាលទោសដល់កូនក្ដីខ្លួន។

- តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ សុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល។

- មានពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ [redacted] SHENG ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ពីបទ៖ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ផ្លូវលេខ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ និងនៅ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២១ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

- ជនជាប់ចោទឈ្មោះ [redacted] ទើបតែមានអាយុ ១៧ឆ្នាំ ដែលត្រូវការអប់រំបន្ថែម ដើម្បីជាធនធានមនុស្សនៅក្នុងសង្គម ហើយច្បាប់បានកំណត់ថា ជាអនីតិជនមានអាយុក្រោម ១៨ឆ្នាំ អាចទទួលបាននូវស្ថានសម្រាលទោស និងកាត់បន្ថយការផ្ដន្ទាទោសពាក់កណ្ដាល។ គប្បីតុលាការលើកយកមាត្រា ១៦០ និង មាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌសម្រេចពិចារណា។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

I-ផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

១-ឈ្មោះ [redacted] SHENG ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិ ចិន (មានសារធាតុជាតិដូចខាងលើ)

កំណត់រយៈពេល ០៣ (បី) ឆ្នាំ។

២-ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ (មានសារធាតុជាតិដូចខាងលើ)

កំណត់រយៈពេល ០១ (មួយ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ ។

ពីបទ៖ រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ផ្លូវលេខ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ និងនៅ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, មាត្រា ១៦០ និងមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ។

II-វត្ថុចាប់យករួមមាន៖

១-ក្រាមពណ៌ សថ្លា ទម្ងន់ ០.១២ g (សូន្យ កណ្តក់សញ្ញា ដប់ពីរ ក្រាម) មេតំហ្វេតាមីន និង ក្រាមពណ៌ សថ្លា ទម្ងន់ ១.៦៧ g (មួយ កណ្តក់សញ្ញា ហុកសិបប្រាំពីរ ក្រាម) កេតាមីន រឹបអូសបំផ្លាញចោល។

២-ទូរស័ព្ទ ០២ គ្រឿង (មិនដំណើរការ)៖ ម៉ាក HUAWEI ពណ៌ ស្វាយ ចំនួន ០១ គ្រឿងរបស់ឈ្មោះ CUI QI SHENG និងម៉ាក ALCATEL ពណ៌ ខ្មៅ ចំនួន ០១ គ្រឿង ពណ៌ ខ្មៅ ចំនួន ០១ គ្រឿងរបស់ឈ្មោះ [redacted] ប្រគល់ឲ្យទៅម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ CUI QI SHENG, ឈ្មោះ [redacted] និងប្រកាសជាអសាធារណៈនៅ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២២។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ចន្ទ ១៣ កើត ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២២

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner